## ២. បង្កើនគុណភាព និងប្រសិទ្ធភាពសេវាអប់រំ

ទន្ទឹមនិងការខិតខំពង្រីកផ្នែកបរិមាណសិស្សចុះឈ្មោះចូលរៀន ក្រសួងបានយកចិត្តទុកដាក់ដល់ការពង្រឹងគុណភាព និងប្រសិទ្ធភាពសេវាអប់រំ ។ ក្រសួងកំពុងធ្វើការកែលំអកម្មវិធីសិក្សាដើម្បីអោយសមស្របទៅនឹងស្ថានភាពអប់រំក្នុងប្រទេស ក្នុងតំបន់ និងក្នុងសកលលោក ក្នុងនោះបានយកចិត្តទុកដាក់ដល់ការរៀបចំស្តង់ដានៃការសិក្សារបស់សិស្ស ការបំពេញការងាររបស់គ្រូបង្រៀន និងបុគ្គលិកសិក្សា ការគិតគូរអំពីម៉ោងបង្រៀន សៀវភៅសិក្សាគោល ផលធៀបសិស្ស-គ្រូ និងផលធៀបសិស្ស-ថ្នាក់រៀនជាដើម ។

ក្រសួងក៏បានជំរុញនិងយកចិត្តទុកដាក់ដល់អត្រាលំហូរសិស្ស រួមមានការបង្កើនអត្រាឡើងថ្នាក់ ការកាត់បន្ថយអត្រាត្រួតថ្នាក់និងអត្រាបោះបង់ការសិក្សាជាដើម ។ ជាមួយនោះ ខិតខំបង្កើនអត្រាឆ្លងភូមិសិក្សាមួយទៅភូមិសិក្សាមួយទៀតដែលខ្ពស់ជាង ដើម្បីរក្សាបានសិស្សនៅក្នុងប្រព័ន្ធនិងបានរៀនចប់ភូមិសិក្សា ហើយខិតខំលើកកំពស់ការងារបង្រៀន ការងារពង្រាយនិងពង្រាយឡើងវិញបុគ្គលិបង្រៀននិងបុគ្គលិកមិនបង្រៀនអោយមានប្រសិទ្ធភាពខ្ពស់ ។

### ២.១. បឋមសិក្សា

គោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា បានយកចិត្តទុកដាក់បង្កើនគុណភាពនិងប្រសិទ្ធភាពនៅបឋមសិក្សាដែលជាមូលដ្ឋានគ្រឹះសម្រាប់បង្កើនការចូលរៀននៅមធ្យមសិក្សា ។ តាមលទ្ធផលជាក់ស្តែងក្នុងឆ្នាំសិក្សា ២០០៣-០៤ អត្រាឡើងថ្នាក់ទី១ សម្រេចបានតែ ៦៤.៨% (ស្រី៦៥.៤%) ធៀបនឹងដៅ ៨៦% (ស្រី៨៦%) ។ អត្រាឡើងថ្នាក់ទី២ បាន៧៣.៤% (ស្រី៧៤.៨%) ធៀបនឹងដៅ ៨៨% (ស្រី៨៨%) និង អត្រាឡើងថ្នាក់ទី ៣ មានត្រឹមតែ ៧៧.៣% (ស្រី៧៨.៩%) ធៀបនឹងដៅ ៨៧% (ស្រី៨៨%) ។

តាមរយៈតួលេខខាងលើ បង្ហាញអោយឃើញថាអត្រាឡើងថ្នាក់មានការកើនឡើង ពិសេសអត្រាឡើងថ្នាក់របស់សិស្សស្រីបានប្រសើរជាអត្រាឡើងថ្នាក់របស់សិស្សប្រុស ។ ប៉ុន្តែ ទោះបីជាមានភាពរីកចម្រើនដូច្នេះក៏ដោយ ក៏លទ្ធផលជាក់មិនទាន់សម្រេចបានតាមដៅដែលគ្រោងទុកនៅឡើយទេ ។



លទ្ធផលក្នុងឆ្នាំសិក្សា២០០៣-០៤ អត្រាត្រួតថ្នាក់ទី១ មាន ២៣.៦% (ស្រី២២.៤%) ធៀបនឹងដៅតែ ៧%ប៉ុណ្ណោះ ។ អត្រាត្រួតថ្នាក់ទី២ ស្មើនឹង១៦.១% (ស្រី១៤.៤%) ធៀបនឹងដៅ ៥% និង អត្រាត្រួតថ្នាក់ទី៣ ស្មើនឹង១៣.២% (ស្រី១១.៣%) ធៀបនឹងដៅ ៥% ។




ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ អត្រាឆ្លងភូមិសិក្សាចូលមធ្យមសិក្សាបឋមភូមិមានការកើនឡើងខ្ពស់នៅឆ្នាំសិក្សា ២០០០-០១ ។ ប៉ុន្តែអត្រានេះមានសភាពថេរ និងបានថយចុះបន្តិចម្តងៗដោយហេតុតែសិស្សបោះបង់នៅថ្នាក់ទី ៥ និងទី ៦ ជាពិសេសសិស្សស្រី សិស្សនៅតំបន់ជួបការលំបាក និងតំបន់ដាច់ស្រយាល ។ នៅឆ្នាំសិក្សា ២០០៤-០៥ នេះ អត្រាឆ្លងភូមិសិក្សាចូលមធ្យមសិក្សាបឋមភូមិមានប្រហែល ៨២% ។

អត្រារៀនចប់បឋមសិក្សា ប្រាប់ជាសញ្ញាមួយអំពីគុណភាពនិងប្រសិទ្ធភាពរបស់ការអប់រំបឋមសិក្សា វាអាចវាស់បានពីលទ្ធផលរួមរបស់កម្រិតអប់រំបឋមសិក្សាទាំងមូល ។ អត្រារៀនចប់បឋមសិក្សាបានកើនពី ៤០.៩%នៅឆ្នាំសិក្សា ១៩៩៩-២០០០ ទៅដល់ ៤៦.៧% ក្នុងឆ្នាំ២០០៣-២០០៤ ។




## ២.២. មធ្យមសិក្សាបឋមភូមិ

ប្រសិទ្ធភាពនៃសេវាអប់រំនៅមធ្យមសិក្សាបឋមភូមិក្នុងពេលបច្ចុប្បន្ននេះ តម្រូវអោយមានការខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីធានាបានលទ្ធផលរៀនសូត្ររបស់សិស្សកាន់តែល្អប្រសើរឡើង ពីព្រោះថាការអប់រំនៅមធ្យមសិក្សាបឋមភូមិជាភូមិសិក្សាដ៏សំខាន់មួយក្នុងកម្រិតអប់រំមូលដ្ឋាន ដែលត្រូវសម្រេចអោយបានតាមគោលដៅអប់រំសម្រាប់ទាំងអស់គ្នានៅឆ្នាំ ២០១៥ ។

ក្នុងឆ្នាំសិក្សា ២០០៣-០៤ អត្រាឡើងថ្នាក់ទី៧ គឺ៧៧.៩% (ស្រី៧៧.១%) ធៀបនឹងដៅ៨៥% ។ អត្រាឡើងថ្នាក់ទី៨ គឺ៧៩.៦% (ស្រី៧៨.៤%) ធៀបនឹងដៅ៨៥% និងអត្រាឡើងថ្នាក់ទី៩ គឺ៦០.១% (ស្រី៦៣.៨%) ធៀបនឹងដៅ៨៥% ។ ទន្ទឹមនឹងនេះ អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ ក៏មិនសម្រេចបានតាមដៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំដែរ ។




ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ អត្រាឆ្លងភូមិសិក្សាចូលមធ្យមសិក្សាទុតិយភូមិមានការកើនឡើងរហូតដល់ឆ្នាំសិក្សា ២០០៣-០៤ ។ ប៉ុន្តែនៅឆ្នាំសិក្សា ២០០៤-០៥ អត្រានេះចុះមកត្រឹម ៥៦% ។




ក្រសួងនឹងធ្វើការពិចារណាឡើងវិញ អំពីការកំណត់ដៅទាំងឡាយដែលមានមហិច្ឆិតាពេក ដើម្បីធានាបាននូវលក្ខណៈប្រាកដនិយម និងអាចអនុវត្តបានសម្រាប់ជាការឆ្លុះបញ្ចាំងអោយឃើញអំពីសកម្មភាពការងារទទួលខុសត្រូវខ្ពស់របស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ និងការទទួលបានលទ្ធផលជាវិជ្ជមាននូវសកម្មភាពបំពេញការងាររបស់ខ្លួន ។

## ២.៣. មធ្យមសិក្សាទុតិយភូមិ

វត្ថុបំណងគោលនយោបាយរបស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ គឺត្រូវកែលំអការចូលរៀន គុណភាព និង ប្រសិទ្ធភាពសេវាអប់រំមធ្យមសិក្សាទុតិយភូមិ ពិសេសការបង្កើនចំនួនសិស្សប្រឡងជាប់ថ្នាក់ទី ១២ នៅតំបន់ជនបទ និង តំបន់ដាច់ស្រយាល ។

ជាទូទៅ អត្រាឡើងថ្នាក់នៅមធ្យមសិក្សាទុតិយភូមិមានការកើនឡើង ពិសេសថ្នាក់ទី ១២ គឺសិស្សឡើងថ្នាក់ សរុបកើនពី ៣៦.៣% ទៅដល់ ៤៥.៥% ចំណែកឯសិស្សស្រីកើនពី ៤២% ទៅដល់ ៥៤% ធៀបនឹងឆ្នាំសិក្សាកន្លងមក ។ អត្រាបោះបង់ការសិក្សាបានថយចុះពី ៤៦% មកត្រឹម ១៧.៩% ការបោះបង់សិក្សារបស់សិស្សស្រីបានថយចុះពី ៤៤% មក ៣១% ។




ចាប់តាំងពីឆ្នាំសិក្សា២០០០-២០០១ មកនឹងឆ្នាំសិក្សា២០០១-២០០២ ចំនួនបេក្ខជនថ្នាក់ទី១២ ដែលត្រូវ ប្រឡងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិមានការកើនឡើងពី ២៩,៦៤៥នាក់ ទៅដល់ ៤៧,១២២នាក់ ។ ប៉ុន្តែទោះជា យ៉ាងនោះក៏ដោយ ក៏ភាគរយបេក្ខជនដែលប្រឡងជាប់សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិបានថយចុះពី ៦៦.៦% មកនៅ ត្រឹម ៣៩.៨%ប៉ុណ្ណោះ ។ គួរកត់សំគាល់ផងដែរក្នុងឆ្នាំសិក្សា២០០២-២០០៣ និង២០០៣-២០០៤ ចំនួនបេក្ខជនប្រឡង សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ និងចំនួនបេក្ខជនប្រឡងជាប់មានការកើនឡើងផងដែរ ។ ជាក់ស្តែងចំនួនបេក្ខជន មកប្រឡងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិសរុបមានចំនួន៣៨,៥៥២នាក់ ។ ភាគរយប្រឡងជាប់គឺ ៤៩% ដែលស្មើ នឹងបេក្ខជនប្រឡងជាប់សញ្ញាប័ត្រចំនួន ១៨,៨៨៣ នាក់ ។

## ២.៤. ការងារបុគ្គលិក និងអភិវឌ្ឍន៍គ្រូបង្រៀន

ក្នុងឆ្នាំសិក្សា២០០៤-០៥នេះ នៅបឋមសិក្សាផលធៀបសិស្ស-គ្រូស្មើនឹង ៥៣.៥ ធៀបនឹងដៅ៥១ ដែលផលធៀបសិស្ស-គ្រូនៅតំបន់ប្រជុំជនស្មើនឹង ៤០.៣ នៅតំបន់ជនបទស្មើនឹង ៥៦.៩ និងនៅតំបន់ដាច់ស្រយាលស្មើនឹង ៥៨.១ ។ កត្តាចំបង១ដែលមានឥទ្ធិពលលើករណីខាងលើនេះ គឺបណ្តាលមកពីការពង្រាយគ្រូបង្រៀនអនុវត្តមិនទាន់បានសមស្រប ធ្វើឱ្យចំនួនគ្រូបង្រៀនមិនគ្រប់គ្រាន់ និងខ្វះសម្ភាររូបវ័ន្តសិក្សាទៀតផង ។

នៅកម្រិតមធ្យមសិក្សាវិញ ផលធៀបសិស្ស-គ្រូក៏មានកម្រិតខ្ពស់ជាងនិយាមដែលបានគ្រោងទុកដែរ ។ ជាក់ស្តែងនៅមធ្យមសិក្សាបឋមភូមិផលធៀបសិស្ស-គ្រូស្មើនឹង២៧.៧ ធៀបនឹងដៅ២៦ ។ នៅមធ្យមសិក្សាទុតិយភូមិវិញ ផលធៀបសិស្ស-គ្រូស្មើនឹង ២៩.៤ ធៀបនឹងដៅ ២៨ ។







គ្រូបង្រៀនបឋមសិក្សាក្នុងតំបន់ដាច់ស្រយាលប្រមាណ ៤% និងនៅតំបន់ជនបទប្រមាណ ៣% ដោយឡែកនៅតំបន់ប្រជុំជន ១% ក្នុងខេត្តកំពង់ចាម សៀមរាប បាត់ដំបង កំពង់ស្ពឺ និងឧត្តរមានជ័យមិនបានទទួលការបណ្តុះបណ្តាល ។ គ្រូបង្រៀនភាគច្រើនមានកម្រិតវប្បធម៌ត្រឹមតែបឋមសិក្សាប៉ុណ្ណោះ ក្នុងនោះគ្រូបង្រៀនចំនួន ៣៤.៥% នៅតាមតំបន់ដាច់ស្រយាល និង៦.៤%ទៀតនៅក្នុងតំបន់ជនបទ ហើយមានគ្រូបង្រៀនចំនួន៤.២% នៅក្នុងតំបន់ទីប្រជុំជនផងដែរ ។

ក្រសួងកំពុងយកចិត្តទុកដាក់បន្ថែមទៀតដល់គ្រូបង្រៀនដែលមិនបានទទួលការបណ្តុះបណ្តាល ដោយធ្វើការពង្រឹងសមត្ថភាព កម្រិតវប្បធម៌ និងវិធីសាស្ត្របង្រៀនដល់គ្រូបង្រៀនទាំងនោះ សំរាប់ធានាថាពួកគាត់អាចផ្តល់សេវាអប់រំដល់កុមារកម្ពុជាគ្រប់រូបប្រកបដោយគុណភាពល្អ និង ប្រសិទ្ធភាពខ្ពស់ ។

## ២.៥. ការផ្គត់ផ្គង់សៀវភៅសិក្សា

ទន្ទឹមនឹងការដោះស្រាយអំពីតម្រូវការគ្រូបង្រៀន ក្រសួងបានយកចិត្តទុកដាក់ផ្គត់ផ្គង់សៀវភៅសិក្សាគោលដោយឥតគិតថ្លៃតាមនិយាមសិស្សម្នាក់សៀវភៅសិក្សាមួយក្បាលក្នុងមួយមុខវិជ្ជាគោល (១:១) សម្រាប់បឋមសិក្សា ។ សិស្សពីរនាក់សៀវភៅសិក្សាមួយក្បាល (២:១) សម្រាប់មធ្យមសិក្សា ដោយឡែកចំពោះសិស្សនៅតំបន់ជួបការលំបាក និងតំបន់ដាច់ស្រយាលសិស្សមួយនាក់សៀវភៅសិក្សាមួយក្បាល(១:១) ។ ជាមួយគ្នានេះដែរ ក្រសួងបានផ្តល់សៀវភៅសម្រាប់គ្រូបង្រៀនក្នុងមួយនាក់មួយក្បាលសម្រាប់គ្រប់មុខវិជ្ជា (១:១) ។

ក្នុងឆ្នាំសិក្សា២០០៤-២០០៥នេះ សាលាបឋមសិក្សាទូទាំងប្រទេសបានទទួលសៀវភៅសិក្សាថ្មីពីក្រសួងសំរាប់:

- ថ្នាក់ទី១ ចំនួន ១៧៥,៣៥៩ក្បាល
- ថ្នាក់ទី២ ចំនួន ១៣៩,៦៧២ក្បាល
- ថ្នាក់ទី៣ ចំនួន ១៤៥,៤៨៥ក្បាល
- ថ្នាក់ទី៤ ចំនួន ១១៦,៨៩៩ក្បាល
- ថ្នាក់ទី៥ ចំនួន ៥៧,៦០៨ក្បាល និង
- ថ្នាក់ទី៦ ចំនួន ៣៩,៣៨២ក្បាល ។ ដោយឡែក សាលាបឋមសិក្សាទាំងអស់នៅក្រុងកែប មិនទាន់បានទទួលសៀវភៅសិក្សាថ្មីទេនៅដើមឆ្នាំសិក្សា២០០៤-០៥នេះ ។ ចំណែកសៀវភៅសិក្សាចាស់ៗដែលប្រមូលពីសិស្សមកវិញហើយនៅប្រើប្រាស់បានប្រហែល៨៧.១%សម្រាប់បឋមសិក្សា និង៨៩.៤%សម្រាប់មធ្យមសិក្សា ។ ចំពោះសៀវភៅណែនាំគ្រូវិញ សាលាបឋមសិក្សាប្រមាណ២៤.៥%បានទទួលសៀវភៅណែនាំគ្រូទាំងគ្រប់កម្រិតថ្នាក់ (ថ្នាក់ទី១-៦) និងនៅសាលាមធ្យមសិក្សាបឋមភូមិមានប្រហែល២.៦% ។ ជាសរុប សាលារៀនគ្រប់ភូមិសិក្សានៅជួបបញ្ហាខ្វះសៀវភៅណែនាំសម្រាប់គ្រូបង្រៀន ហើយការគ្រប់គ្រងសៀវភៅសិក្សាទៀតសោត នៅមិនទាន់បានដិតដល់នៅឡើយ ។

## ២.៦. ការអភិវឌ្ឍសម្ភាររូបវ័ន្តអប់រំ

វត្ថុបំណងជាយុទ្ធសាស្ត្រដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ គឺធានាថាត្រូវមានសាលារៀនបឋមសិក្សាដែលមានពីថ្នាក់ទី១ដល់ទី៦នៅជិតទីលំនៅរបស់ប្រជាជន និងត្រូវកាត់បន្ថយចំនួនសាលារៀនដែលមិនគ្រប់កម្រិតថ្នាក់ ។ ជាលទ្ធផលក្នុងឆ្នាំសិក្សា២០០៤-០៥នេះ សាលាបឋមសិក្សាមិនគ្រប់កម្រិតថ្នាក់មានចំនួន ១,៩៣៤ ឬស្មើ ៣១.៣% ដែលចំនួននេះតិចជាងសាលាបឋមសិក្សាមិនគ្រប់កម្រិតកាលពីឆ្នាំសិក្សា២០០៣-០៤ ដែលមានដល់ទៅ ២,១៧៩ ឬស្មើនឹង៣៥.៩% នៃចំនួនសាលាបឋមសិក្សាសរុបទូទាំងប្រទេស។ ក្នុងនោះ សាលារៀនដែលមានត្រឹមថ្នាក់ទី១ មាន៦.៥% ។ សាលារៀនមានដល់ថ្នាក់ទី២ មានចំនួន១៩.៨% ។ សាលារៀនមានដល់ថ្នាក់ទី៣ ចំនួន២១.៩%។ សាលារៀនមានដល់ថ្នាក់ទី៤ ចំនួន២៦.៣% និងសាលារៀនចំនួន២៥.៦% មានដល់ថ្នាក់ទី៥ ។

ជាទូទៅ ស្ថានភាពសាលាបឋមសិក្សាមិនគ្រប់កម្រិតមានច្រើននៅតំបន់ជនបទនិងដាច់ស្រយាល ។ ក្នុងតំបន់ដាច់ស្រយាលសាលាមិនគ្រប់កម្រិតមានចំនួន៦៦.0% ហើយនៅតាមតំបន់ជនបទមានចំនួន២៩.៦% ។ ដោយឡែកស្ថានភាពមានសាលាបឋមសិក្សាមិនគ្រប់កម្រិតមានលក្ខណៈធ្ងន់ធ្ងរនៅក្នុងខេត្តមួយចំនួនដូចជាៈ ខេត្តរតនគិរីមានដល់ទៅ៨១.0% ខេត្តមណ្ឌលគិរីមាន៧៧.១% ព្រះវិហារមានចំនួន៦១.៧% ខេត្តស្ទឹងត្រែងមាន៥៨.៤% ខេត្តកោះកុងមាន៥៤.៦% ខេត្តឧត្តរមានជ័យមាន៥២.២% ខេត្តកំពង់ធំមាន៥១.២% ខេត្តកំពង់ចាមមាន៤៦.៣% និងខេត្តក្រចេះមាន៤៣.៥% ។

ក្រសួងអប់រំខិតខំបំពេញបន្ថែមថ្នាក់រៀន និងផ្តល់សម្ភាររូបវ័ន្តអប់រំសម្រាប់ថ្នាក់ទី៧-៩ និងថ្នាក់ទី១០-១២ នៅតាមតំបន់ដែលខ្វះសេវាអប់រំកម្រិតនេះ និងនៅក្នុងតំបន់ដែលមានចំនួនសិស្សច្រើនលើសលុប ។

ក្រសួងទទួលបានបទពិសោធន៍ល្អៗ និងសមត្ថភាពយល់ដឹងក្នុងការគ្រប់គ្រងកម្មវិធីជាមូលធន ជាពិសេសជំនួយបច្ចេកទេសក្នុងការសាងសង់សាលារៀននិងការកសាងសមត្ថភាព ហើយសង្ឃឹមថាការគ្រប់គ្រងកម្មវិធីទាំងនេះនឹងត្រូវរៀបចំដោយផ្អែកលើមូលដ្ឋានករណីនីមួយៗ រួមទាំងការធ្វើវិមជ្ឈការកាន់តែខ្លាំងលើការផ្តល់ហិរញ្ញវត្ថុសំរាប់អភិវឌ្ឍន៍សម្ភាររូបវ័ន្តដល់ខេត្ត-ក្រុង ។ ក្រសួងអប់រំ យុវជន និងកីឡា និងអ្នកផ្តល់ជំនួយសំខាន់ៗក៏នឹងធ្វើការពិចារណាផងដែរលើវិសាលភាពផ្តល់ធនធានថវិកា សំរាប់ការអភិវឌ្ឍនិងការរៀបចំការគ្រប់គ្រងកម្មវិធីសម្ភាររូបវ័ន្ត ដើម្បីប្រើប្រាស់អោយអស់លទ្ធភាពនិងសមត្ថភាពក្នុងការគ្រប់គ្រងសម្ភាររូបវ័ន្តដែលមានស្រាប់របស់ក្រសួងអប់រំ យុវជន និងកីឡា ។